# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

ស្ដីពីការបន្តព្យួរកិច្ចសន្យាការងាររវាងតំណាងកម្មករនិយោជិត និងក្រុមហ៊ុន ម៉េម៉ីរអង្គរ (ខេមបូឌា), សាខា សណ្ឋាគារម៉េម៉ីរសៀមរាប កាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២០ វេលាម៉ោង ០៩ និង ៣០នាទី មានការប្រជុំស្ដីពីការព្យួរកិច្ចសន្យាការងារ នៅក្រុមហ៊ុន ម៉េម៉ីរអង្គរ (ខេមបូឌា), សាខា សណ្ឋាគារម៉េម៉ីរសៀមរាប មានអាស័យដ្ឋានស្ថិតនៅ ភូមិតាកុល សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប។

### សមាសភាពចូលរួមក្នុងអង្គប្រជុំមាន៖

| **ក. តំណាងភាគីនិយោជក** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| លោក បូរ សំប៊ុន | នាយកគ្រប់គ្រងទូទៅ | ០៦៩ ៨៩០ ៧៧៧ |
| អ្នកស្រី អ៊ុង សុគន្ធារី | ប្រធានផ្នែកធនធានមនុស្ស | ០៦៩ ៤១០ ៧៧៧ |

| **ខ. តំណាងភាគីកម្មករនិយោជិត** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| លោក ឆេង ឆង | ប្រតិភូបុគ្គលិកពេញសិទ្ធិ | ០៦៩ ៤៧៥ ៧៧៧ |
| អ្នកស្រី បុង ពិសី | ប្រតិភូបុគ្គលិកជំនួយ | ០៦៩ ៤៦៤ ៧៧៧ |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធទៅនឹង ការព្យួរកិច្ចសន្យាការងារឲ្យបានសមស្របតាម សេចក្ដីណែនាំលេខ ០៤៥/២០កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ភាគីទាំងពីរបានឯកភាពយល់ព្រមបន្តព្យួរកិច្ចសន្យាការងារចំពោះកម្មករនិយោជិតចំនួន៦៣នាក់ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ ដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២០ ដោយទទួលបាននូវប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗ ចំនួន ៤០ដុល្លាអា-មេរិក ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។ សំរាប់ក្រុមហ៊ុន មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្ដល់ប្រាក់ឧបត្ថមបន្ថែមទៅដល់កម្មករនិយោជិតក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារតែក្រុមហ៊ុនបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីជំងឺ COVID-19 ធ្វើឲ្យបាត់បង់ប្រាក់ចំណូលហើយបង្ខំចិត្តផ្អាកអាជីវកម្មមួយរយៈ។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ១៦ និង ៣០នាទី រសៀល ថ្ងៃ ខែ ឆ្នាំដដែល ដោយមានការចុះហត្ថលេខា ព្រមព្រៀងរបស់តំណាងទាំងអស់ដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខាដូចខាងក្រោម៖

**តំណាងភាគីនិយោជក**

ហត្ថលេខា/ស្នាមមេដៃ

**លោក បូរ សំប៊ុន**

នាយកគ្រប់គ្រងទូទៅ

**អ្នកស្រី អ៊ុង សុគន្ធារី**

ប្រធានផ្នែកធនធានមនុស្ស

**តំណាងភាគីកម្មករនិយោជិត**

ហត្ថលេខា/ស្នាមមេដៃ

**លោក ឆេង ឆង**

ប្រតិភូបុគ្គលិកពេញសិទ្ធិ

**អ្នកស្រី ប៊ុង ពិសី**

ប្រតិភូបុគ្គលិកជំនួយ